សំរិទ្ធិស័ក

SAMRITHISAK

ដើម្បីអាជីវកម្មឈានមុខគេជានិច្ច







# ២០១៨

# របាយការណ៍ប្រចាំឆ្នាំ

www.samrithisak.com

# មាតិកា


សំរីទ្ធិស័ក - ទស្សនវិស័យ និង បេសកកម្ម .................................. 1
សំរីទ្ធិស័ក ពណ៌នាសង្ខេប .......................................................... 1
សូចនាករស្ថានភាពហិរញ្ញវត្ថុសង្ខេប ........................................ 2
សូចនាករស្ថានភាពប្រតិបត្តិការសង្ខេប...................................... 4
គណៈប្រតិបត្តិ ............................................................................ 5
ក្រុមប្រឹក្សាភិបាល ...................................................................... 5
គណៈកម្មធិការប្រតិបត្តិ ............................................................... 7
គំនូសតាងរចនាសម្ព័ន្ធ ............................................................. 10
សេចក្តីសង្ខេបអំពីគ្រឹះស្ថាន........................................................11
របាយការណ៍ក្រុមប្រឹក្សាភិបាល............................................... 12
របាយការណ៍សវនករឯករាជ្យ..................................................15
អាស័យដ្ឋានការិយាល័យកណ្តាល និងសាខា ........................... 65

## សំរឹទ្ធិស័ក - ទស្សនវិស័យ និង បេសកកម្ម




## សំរឹទ្ធស័ក ពណ៌នាសង្ខេប

បង្កើតឡើងក្នុងឆ្នាំ ២០១០ ដោយមានឈ្មោះជាផ្លូវការ " **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត** ក្រោមគំនិតផ្តួចផ្តើមរបស់ លោក តាំង ងួន និងវិនិយោគិនខ្មែរចំនួនបួនរូបទៀត។

**សំរឹទ្ធិស័ក** បានផ្តល់នូវសេវាកម្មផ្នែកឥណទានដល់អតិជនដែលកំពុងមានតម្រូវការផ្នែកហិរញ្ញវត្ថុ ដូចជាឥណទានដែលមានអាយុកាលវែង និងអាយុកាលខ្លីទៅតាមស្ថានភាពជាក់ស្តែង។



## ដើមទុន (ដុល្លារអាមេរិក)




## សូចនាករស្ថានភាពហិរញ្ញវត្ថុសង្ខេប

| | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | ៨.៥២២.៧២២ | ១១.៦៣០.០៩៣ | ១៤.៧៥៧.៣២១ | ២៤.៧០៩.២៤៧ |
| មូលធនភាគទុនិកសរុប | ៣.៥៧០.៣១៨ | ៣.៩៨៧.៨៥៧ | ៦.៧៨៤.៤៥៧ | ១២.៥១០.៦៧០ |
| ឥណទានសុទ្ធ | ៧.៧២៣.៧០០ | ១០.៦៤៨.៤៩២ | ១៣.៣១៩.៤០៨ | ២៣.០២២.៤២៧ |
| ចំនួនអតិថជន | ១២៤៧ | ១៨៥៩ | ២៧៩៧ | ២៨៧៧ |

# របាយការណ៍ហិរញ្ញវត្ថុសង្ខេប




| | |
|---|---|
| អត្រាឥណទានមិនដំណើរការ | ០.៨៩% |
| អនុបាតចំណាយប្រតិបការ | ១.២៨% |
| អនុបាតចំណាយហិរញ្ញវត្ថុ | ០.២០% |
| ផលលើទ្រព្យសកម្ម (ROA) | ២.៦៨% |
| ផលលើមូលធន (ROE) | ៥.៥៨% |

# របាយការណ៍ចំណេញខាតសង្ខេប



# សូចនាករស្ថានភាពប្រតិបត្តិការសង្ខេប

## ឥណទានតាមប្រភេទជំនួញ






# គណៈប្រតិបត្តិ

## គណៈកម្មការប្រតិបត្តិ

* **លោក តាំង ងួន**

  តែងតាំងជាប្រធាននាយកប្រតិបត្តិនៅឆ្នាំ ២០១០

* **លោក ប៊ុន ជីជាវ**

  តែងតាំងជាអនុប្រធាននាយកប្រតិបត្តិនៅឆ្នាំ ២០១០

* **លោក អ៊ុក សុវត្ថិភាព**

  តែងតាំងជានាយកគ្រប់គ្រងទូទៅនៅឆ្នាំ ២០១៨

## ក្រុមប្រឹក្សាភិបាល

* **លោក តាំង ហុង**

  បានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៅឆ្នាំ ២០១៧

* **លោក តាំង ងួន**

  បានតែងតាំងជាអនុប្រធានក្រុមប្រឹក្សាភិបាលនៅឆ្នាំ ២០១៧

* **លោក ជាស៊ុ វណ្ណលាង**

  បានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៅឆ្នាំ ២០១០

# ក្រុមប្រឹក្សាភិបាល

## លោក តាំង ហុង ប្រធានក្រុមប្រឹក្សាភិបាល



**លោក តាំង ហុង** ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ **ស៊ីវិទ្ធិស័ក** នៅឆ្នាំ ២០១៧។ គាត់កើតនៅឆ្នាំ ១៩៧០ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩៤ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិន ម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្គតធីងឡាយគ្រុប ខូអិលធីឌី និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន មេគង្គគ្លីននីគ្រុប ខូអិលធីឌី។ គាត់បាន បញ្ចប់ បរិញ្ញាបត្រហិរញ្ញវត្ថុ និងធនាគារ។

## លោក តាំង ងួន អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក



**លោក តាំង ងួន** ជាអនុប្រធានក្រុមប្រឹក្សាភិបាលរបស់ **សំរឹទ្ធិស័ក** ក្នុងឆ្នាំ ២០១៧។ គាត់បានកើតនៅឆ្នាំ ១៩៦៩ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិកនិងសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្តតផឹងឡាយគ្រុប ខូអិលធីឌី និងក្រុមហ៊ុនមេគង្គគ្លីននីគ្រុប ខូអិលធីឌី។ លោក តាំង ងួន បានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងទូទៅ។

## លោក ជា ស៊ីវណ្ណលាង សមាជិកក្រុមប្រឹក្សាភិបាល

**លោក ជា ស៊ីវណ្ណលាង** ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ **សំរឹទ្ធិស័ក** ចាប់តាំងពីគាត់ចូលបម្រើការងារនៅក្នុងក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ ២០១០។ គាត់បានកើតនៅក្នុងឆ្នាំ ១៩៥៥ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជា វិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិក និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនមេគង្គគ្លីននីគ្រុប ខូអិលធីឌី និងក្រុមហ៊ុនស៊ីហ្វេសអាសអេស ខូអិលធីឌី។ លោកបានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម។



# គណៈកម្មាធិការប្រតិបត្តិ

## លោក តាំង ងួន អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក



លោក **តាំង ងួន** ជាអនុប្រធានក្រុមប្រឹក្សាភិបាលរបស់ **សំរឹទ្ធិស័ក** ក្នុងឆ្នាំ ២០១៧។ គាត់បានកើតនៅឆ្នាំ ១៩៦៩ មានដើមកំណើតជាជនជាតិខ្មែរ។ ចាប់តាំងពីឆ្នាំ ១៩៩០ រហូតដល់សព្វថ្ងៃ លោកជាវិនិយោគិនម្នាក់ដែលទទួលបានជោគជ័យ។ លោកជាភាគទុនិកនិងសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្តតធីងឡាយគ្រុប ខូអិលធីឌី និងក្រុមហ៊ុនមេគង្គគ្លីននីវគ្រុប ខូអិលធីឌី។ លោក តាំង ងួន បានបញ្ចប់បរិញ្ញាបត្រគ្រប់គ្រងទូទៅ។

## លោក ប៊ុន ជីជាវ អនុប្រធាននាយកប្រតិបត្តិ

**លោក ប៊ុន ជីជាវ** កើតនៅឆ្នាំ ១៩៨០ នៅខេត្តកំពង់ចាម។ លោកបានចូលបម្រើការងារជាមួយ **សំរឹទ្ធិស័ក** ក្នុងឆ្នាំ២០១០ មានតួនាទីជាអនុប្រធាននាយកប្រតិបត្តិ។ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកធនាគារនិងហិរញ្ញវត្ថុ នៅសាកវិទ្យាល័យបៀលប្រាយ និងកំពុងបន្តសិក្សាថ្នាក់អនុបណ្ឌិតគ្រប់គ្រងទូទៅ នៅសាកវិទ្យល័យបៀលប្រាយ។ លោក បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដែលទាក់ទងនឹងការគ្រប់។ មុនគាត់ចូលបំរើការងារក្នុង សំរឹទ្ធស័ក គាត់ធ្លាប់បានបំរើការងារជាប្រធានទីផ្សារ នៅក្រុមហ៊ុនថៃសារ៉ាកាលពីឆ្នាំ ២០០៤ នៅក្នុងប្រទេសកម្ពុជា។



## លោក អ៊ុក សុវត្ថិភាព នាយកគ្រប់គ្រងទូទៅ



**លោក អ៊ុក សុវត្ថិភាព** បានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សំរិទ្ធិស័ក** លីមីតធីត នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧។ លោកបានបញ្ចប់ការសិក្សាត្រឹមកម្រិតថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកធានាគារនិងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យបៀលប្រាយ ក្រុងភ្នំពេញ។ ក្រៅពីនេះលោកបានចូលរួមវគ្គបណ្ដុះបណ្ដាលជាច្រើនដូចជា ភាពជាអ្នកដឹកនាំ ប្រសិទ្ធភាពក្នុងការគ្រប់គ្រងឥណទាន ប្រសិទ្ធភាពក្នុងការគ្រប់គ្រងសាខា ការគ្រប់គ្រងធនធានមនុស្ស វិធីសាស្រ្តក្នុងការដោះស្រាយបញ្ហា និង វគ្គបណ្ដុះបណ្ដាលជាច្រើនទៀតដែលទាក់ទងនឹងការអនុវត្តការងារប្រចាំថ្ងៃ។ មុនពេលមកបំពេញការងារជាមួយសំរឹទ្ធិស័ក លោកបានធ្វើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់អស់រយៈពេល១២ឆ្នាំ ក្នុងតួនាទីរួមមាន នាយកភូមិភាគ នាយកសាខានិងមន្រ្តីឥណទាន។

## សៀង គឹមសេង នាយក នាយកដ្ឋានព័ត៌មានវិទ្យា



លោក សៀង គឹមសេង បានចូលរួមជាមួយ **សំរិទ្ធិស័ក** ជា ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៅខែធ្នូ ឆ្នាំ២០១៧។ មុនចូលរួមជាមួយ សំរិទ្ធិស័ក គាត់បានបំរើការងារជាមួយ ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនដោយកាន់មុខដំណែងជា អ្នកព្រឹក្សាយោបល់ផ្នែក ប្រព័ន្ធគ្រប់គ្រង់ធនាគា នាយកផ្នែកពត៌មានវិទ្យា ក្នុងចន្លោះឆ្នាំ ២០០៦ ដល់ ២០១៧ ហើយ ជាប្រធានគ្រប់គ្រង់គំពោងប្រព័ន្ធពត៌មានវិទ្យា ជាគ្រូបង្រៀនសរសេរកូដនៅសកលវិទ្យាល័យ ក្នុងកំឡុងឆ្នាំ ២០០១ ដល់ ២០០៦។ គាត់បានបញ្ចប់ការសិក្សាបរិញ្ញាប័ត្រផ្នែកពត៌មានវិទ្យា ហើយបច្ចុប្បន្នកំពុងបន្តការសិក្សា ថ្នាក់អនុបណ្ឌិតផ្នែកពត៌មានវិទ្យាផងដែរ។ គាត់ក៏បានចូលរួមវគ្គបណ្ដុះបណ្ដាលផ្សេងៗទៀតដូចជា ឥទ្ធិពលនៃភាពជោគជ័យផ្ទាល់ខ្លួន អភិបាលកិច្ចអាជីវកម្មស្តង់ដារ និងជំនាញថ្នាក់ដឹកនាំ ដើម្បីភាពជោគជ័យ។

## តាន់ ហុកហេង នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង



លោក តាន់ ហុកហេង ជា នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សំរឹទ្ធិស័ក** លីមីតធីត នៅក្នុងខែមករាឆ្នាំ ២០១៨ ក្នុងមុខតំណែងជា នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង។ មុនពេលចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត លោក តាន់ ហុកហេង មានបទពិសោធន៍ជា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃជាមួយធនាគារឯកទេសនិងគ្រឹះស្ថានមីក្រូហិរញ្ញផ្សេងៗចាប់តាំងពីឆ្នាំ២០១១និងជាមន្ត្រីសវនករជាន់ខ្ពស់ពីឆ្នាំ២០០៩។ លោក តាន់ ហុកហេង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញ គណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ ២០០៦។ ក្រៅពីនេះលោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា៖ កម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងធនាគារ ( Card MFI and Bank) នៅប្រទេសពីលីពីន ហើយនិងជំនាញសវនកម្មនិងអភិបាលកិច្ចព័ត៌មានវិទ្យាជំនាញឯកទេសកុំព្យូទ័រនៅវិទ្យាស្ថានសាន់រ៉ាយស៍។និងវគ្គសិក្សាទាក់ទិននឹង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ផ្សេងៗទៀត។គាត់អាចនិយាយយ៉ាងល្អជាភាសាអង់គ្លេសនិងភាសាខ្មែរ។



# គំនូសតាងរចនាសម្ព័ន្ធ



# សេចក្តីសង្ខេបអំពីគ្រឹះស្ថាន

| | |
|---|---|
| ឈ្មោះគ្រឹះស្ថាន | ៖ គ្រឹះស្ថាន សំរឹទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត |
| ប្រភេទអាជីវកម្ម | ៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ចុះបញ្ជីលេខ | ៖ Co-0485 KH/2010 |
| ការិយាល័យចុះបញ្ជី | ៖ ផ្ទះលេខ ៥០២ហ្សេ ៥០២ ហាស់ មហាវិថីព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| សវនករឯករាជ្យ | ៖PricewaterhouseCoopers (Cambodia) Ltd. |
| បុគ្គលិក | ២០៦៖ បុគ្គលិកសរុបមានចំនួន |

**Gender Diversity in 2018**



# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សំរិទ្ធិស័ក លីមីតធីត (ហៅកាត់ថា "ក្រុមហ៊ុន") សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

## អំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សំរិទ្ធិស័ក លីមីតធីត គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co-០៤៨៥ KH/២០១០ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០។ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតាមសហគមន៍ ដោយផ្តោតលើការបង្កើនចំណូលរបស់ប្រជាពលរដ្ឋ តាមរយៈការជំរុញសកម្មភាពអាជីវកម្មសហគ្រាសខ្នាតតូច និងមធ្យម ពាណិជ្ជកម្ម និងកសិកម្មជនបទ ដោយការប្រើប្រាស់សេវាកម្មប្រាក់កម្ចី និងប្រាក់សន្សំដែលមានអត្រាការប្រាក់សមរម្យ និងធានានិរន្តរភាពរយៈពេលវែងសម្រាប់ក្រុមហ៊ុន និងអតិថិជនរបស់ខ្លួន។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល នៅលើទំព័រទី១០។

## ដើមទុន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ក្រុមហ៊ុនមានដើមទុន ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ហើយបានបង់រួចរាល់ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់១៥ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ឥណទានអតិថិជនអាក្រក់ និងសង្ស័យ

មុនការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យពាក់ព័ន្ធទៅនឹងការជម្រះឥណទានអតិថិជនអាក្រក់ចេញពីបញ្ជី និងការធ្វើសំវិធានធនឥណទានអតិថិជនអាក្រក់ និងសង្ស័យ និងបានយល់ស្របថារាល់ឥណទានអតិថិជនអាក្រក់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងកត់ត្រាសំវិធានធនពេញលេញសម្រាប់ឥណទានអតិថិជនអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទរបាយការណ៍នេះ និងផ្អែកលើការយល់ដឹងដ៏សមស្រប ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុ-ការណ៍ណាមួយដែលនឹងបណ្តាលឱ្យចំនួនឥណទានអតិថិជនអាក្រក់ដែលបានជម្រះពីបញ្ជី ឬ ចំនួនសំវិធានធនឥណទានអតិថិជនអាក្រក់ និងសង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

**ទ្រព្យសកម្ម**

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយ ក្រៅពីបំណុលដែលទំនងជាមិនអាចបង្វិលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និង ផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ពុំត្រឹមត្រូវជាសារវន្តនោះទេ។

**បំណុលយថាភាព និងបំណុលផ្សេងៗ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីដំណាច់ឆ្នាំមក ក្រៅពីប្រតិបត្តិការដែលបានកើតឡើងនៅក្នុងដំណើរការអាជីវកម្មធម្មតា។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនបានក្លាយជាការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ការិយបរិច្ឆេទដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

**ការប្រែប្រួលកាលៈទេសៈ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល គ្មានការកើតឡើងនូវប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ក្នុងចន្លោះពេលដំណាច់ឆ្នាំរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលនាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ឆ្នាំដែលបានរាយការណ៍នេះទេ។

**ក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការក្នុងឆ្នាំ និងគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| លោក តាំង ហុង | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក តាំង ងួន | អនុប្រធានក្រុមប្រឹក្សាភិបាល |
| លោក ជាវ ស៊ីវណ្ណលាង | សមាជិកក្រុមប្រឹក្សាភិបាល |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលប្រតិបត្តិការ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ តម្រូវឱ្យក្រុមប្រឹក្សាភិបាល ៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យមានភាពស៊ីសង្វាក់គ្នា។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឱ្យមានភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវធានាថាការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតយ៉ាងសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មក្នុងពេលអនាគតដ៏ខ្លី។

៥. ចែងគោលការណ៍ទូទៅរបស់ក្រុមហ៊ុន និងអនុម័តនូវរាល់សេចក្តីសម្រេចចិត្ត និងសកម្មភាពរបស់ក្រុមប្រឹក្សាភិបាលដែលមានឥទ្ធិពលជាសារវន្ត លើប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាគោលការណ៍ទាំងនេះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

ជ. ក្រុមប្រឹក្សាភិបាល

**លោក តាំង ហុង**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី២៩ ខែ០៣ ឆ្នាំ២០១៩

# របាយការណ៍សវនករឯករាជ្យ

ជូនភាគទុនិក គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត

**មតិយោបល់របស់យើងខ្ញុំ**

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត(ហៅកាត់ថា "ក្រុមហ៊ុន") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

**របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម**

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនភាគទុនិកសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

**មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ**

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា "ស្តង់ដារសវនកម្ម")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ *"ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ"* នៅក្នុងរបាយការណ៍របស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

**ឯករាជ្យ**

យើងខ្ញុំមានឯករាជ្យពីក្រុមហ៊ុន ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និង ក្រមសីលធម៌ វគសក។

**ព័ត៌មានផ្សេងៗ**

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន របាយការណ៍ក្រុមប្រឹក្សាភិបាលនិងឧបសម្ព័ន្ធស្តីពីតម្រូវការនៃប្រកាសរបស់ធនាគារកណ្តាល ប៉ុន្តែឧបសម្ព័ន្ធទាំងនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងទទួលខុសត្រូវលើការត្រួត ពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាភាពងឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីគាក់តែងនីតិវិធីសវនកម្មដែលសមស្រប ទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្ដាលឱ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្ដីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្ដាលឱ្យក្រុមហ៊ុនឈប់បន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្ដែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

**ជ. ក្រុមហ៊ុន** PricewaterhouseCoopers ( Cambodia ) Ltd.

**គុយ លីម**

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ៖ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩

**គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័កលីមីតធីត**

**តារាងតុល្យការ**
**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

| | កំណត់សម្គាល់ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ១០៨.៦៧៤ | ៤៣៦.៦៥៣ | ១៧១.១៤៨ | ៦៩០.៩២៤ |
| សមតុល្យសាច់ប្រាក់ជាមួយភ្នាក់ងារ | ៥ | ១៦៤.១៩១ | ៦៥៩.៧១៩ | ១០៧.៨៨២ | ៤៣៥.៥១៩ |
| សមតុល្យនៅធនាគារកណ្តាល | ៦ | ៥០២.៧៩៦ | ២.០២០.២៣៤ | ២៥១.៤៧១ | ១.០១៥.១៨៨ |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៧ | ១០៨.០២៥ | ៤៣៤.០៤៤ | ៣១៦.៣៧០ | ១.២៧៧.១៨៦ |
| ឥណទានអតិថិជន | ៨ | ២៣.០២២.៤២៧ | ៩២.៥០៤.១១២ | ១៣.៣១៩.៤០៨ | ៥៣.៧៧០.៤៥០ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ២៥០.២៦២ | ១.០០៥.៥៥៣ | ១៤៦.២៦០ | ៥៩២.០៦៦ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | ៤៧៩.១៣៩ | ១.៩២៥.១៨១ | ៤៣៩.៨៤៨ | ១.៧៧៥.៦៦៦ |
| ទ្រព្យសកម្មអរូបី | ១១ | ៣.២៤៦ | ១៣.០៤២ | ៤.៥៣៤ | ១៨.៣០៤ |
| ពន្ធពន្យារទ្រព្យសកម្ម | ២៣ | ៧០.៤៨៧ | ២៨៣.២១៧ | - | - |
| **ទ្រព្យសកម្មសរុប** | | ២៤.៧០៩.២៤៧ | ៩៩.២៨១.៧៥៥ | ១៤.៧៥៧.៣២១ | ៥៩.៥៧៥.៣០៣ |
| **បំណុល និងមូលធនភាគទុនិក** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | ១២ | ១១.៦៩៧.៥៥៦ | ៤៧.០០០.៧៨០ | ៧.៦៨៦.៤២៦ | ៣១.០៣០.១០២ |
| បំណុលផ្សេងៗ | ១៣ | ១៧៥.១៤៥ | ៧០៣.៧៣៣ | ២២៣.៤៥៤ | ៩០២.០៨៤ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ២៣ | ២៣៣.៨០៩ | ៩៣៩.៤៤៥ | ៦២.៩៨៤ | ២៥៤.២៦៦ |
| កាតព្វកិច្ចអតីតភាពការងាររបស់បុគ្គលិក | ១៤ | ៩២.០៦៧ | ៣៦៩.៩២៥ | - | - |
| **បំណុលសរុប** | | ១២.១៩៨.៥៧៧ | ៤៩.០១៣.៨៨៣ | ៧.៩៧២.៨៦៤ | ៣២.១៨៦.៤៥២ |
| **មូលធនភាគទុនិក** | | | | | |
| ដើមទុន | ១៥ | ១០.០០០.០០០ | ៤០.១៨០.០០០ | ៥.០០០.០០០ | ២០.១៨៥.០០០ |
| ចំណេញរក្សាទុក | | ២.៥១០.៦៧០ | ១០.០៨៧.៨៧២ | ១.៧៨៤.៤៥៧ | ៧.២០៣.៨៥១ |
| **មូលធនភាគទុនិកសរុប** | | ១២.៥១០.៦៧០ | ៥០.២៦៧.៨៧២ | ៦.៧៨៤.៤៥៧ | ២៧.៣៨៨.៨៥១ |
| **បំណុល និងមូលធនភាគទុនិកសរុប** | | ២៤.៧០៩.២៤៧ | ៩៩.២៨១.៧៥៥ | ១៤.៧៥៧.៣២១ | ៥៩.៥៧៥.៣០៣ |

## គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត

## របាយការណ៍លទ្ធផល
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់ | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | **សម្គាល់** | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ចំណូលការប្រាក់ | ១៦ | ៣.០៤២.៦០៦ | ១២.២២៥.១៩១ | ១.៩៨០.០៦២ | ៧.៩៩៣.៥១០ |
| ចំណាយការប្រាក់ | ១៧ | (៤៣៤.៥៣២) | (១.៧៤៥.៩៥០) | (៣០៦.៤៨១) | (១.២៣៧.២៦៤) |
| **ចំណូលការប្រាក់សុទ្ធ** | | ២.៦០៨.០៧៤ | ១០.៤៧៩.២៤១ | ១.៦៧៣.៥៨១ | ៦.៧៥៦.២៤៦ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១៨ | ៥៣៥.១៦២ | ២.១៥០.២៨១ | ២៥១.៦៥២ | ១.០១៥.៩១៩ |
| **ចំណូលប្រតិបត្តិការ** | | ៣.១៤៣.២៣៦ | ១២.៦២៩.៥២២ | ១.៩២៥.២៣៣ | ៧.៧៧២.១៦៥ |
| ចំណាយបុគ្គលិក | ១៩ | (១.៣១៥.៤៧៤) | (៥.២៨៥.៥៧៥) | (១.០០៨.៥៦៣) | (៤.០៧១.៥៦៩) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និង<br>រំលស់ទ្រព្យសកម្មអរូបី | ២០ | (១២៦.៧៣៨) | (៥០៩.២៣៣) | (១២៧.១៧០) | (៥១៣.៣៨៥) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២១ | (៥៣៣.៣២៤) | (២.១៤២.៨៩៦) | (៣៤១.៧៦៦) | (១.៣៧៩.៧១០) |
| **ចំណេញប្រតិបត្តិការ** | | ១.១៦៧.៧០០ | ៤.៦៩១.៨១៨ | ៤៤៧.៧៣៤ | ១.៨០៧.៥០១ |
| សំវិធានធនខាតការថយចុះតម្លៃ នៃឥណទាន<br>បុរេប្រទាន និងហិរញ្ញប្បទាន | ២២ | (២៤៤.៧៦៨) | (៩៨៣.៤៧៨) | (៦៦.៦២៦) | (២៦៨.៩៦៩) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | ៩២២.៩៣២ | ៣.៧០៨.៣៤០ | ៣៨១.១០៨ | ១.៥៣៨.៥៣២ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៣ | (១៩៦.៧១៩) | (៧៩០.៤១៧) | (៨៤.៥០៨) | (៣៤១.១៥៩) |
| **ចំណេញក្នុងឆ្នាំ** | | ៧២៦.២១៣ | ២.៩១៧.៩២៣ | ២៩៦.៦០០ | ១.១៩៧.៣៧៣ |

**គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សំរីទ្ធិស័ក លីមីតធីត**

**របាយការណ៍បម្រែបម្រួលមូលធនភាគទុនិក**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

| | បែងចែកទៅឱ្យម្ចាស់របស់ក្រុមហ៊ុន | | |
|---|---|---|---|
| | | ចំណេញ | |
| | ដើមទុន | រក្សាទុក | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **សម្រាប់ដំណាច់ឆ្នាំទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ២.៥០០.០០០ | ១.៤៨៧.៨៥៧ | ៣.៩៨៧.៨៥៧ |
| ដើមទុនបានបង់ | ២.៥០០.០០០ | - | ២.៥០០.០០០ |
| ចំណេញក្នុងឆ្នាំ | - | ២៩៦.៦០០ | ២៩៦.៦០០ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | ៥.០០០.០០០ | ១.៧៨៤.៤៥៧ | ៦.៧៨៤.៤៥៧ |
| **គិតជាពាន់រៀល** | ២០.១៨៥.០០០ | ៧.២០៣.៨៥១ | ២៧.៣៨៨.៨៥១ |
| **សម្រាប់ដំណាច់ឆ្នាំទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ | ៥.០០០.០០០ | ១.៧៨៤.៤៥៧ | ៦.៧៨៤.៤៥៧ |
| ដើមទុនបានបង់ | ៥.០០០.០០០ | - | ៥.០០០.០០០ |
| ចំណេញក្នុងឆ្នាំ | - | ៧២៧.៤១៦ | ៧២៧.៤១៦ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ១០.០០០.០០០ | ២.៥១១.៨៧៣ | ១២.៥១១.៨៧៣ |
| **គិតជាពាន់រៀល** | ៤០.១៨០.០០០ | ១០.០៩២.៧០៦ | ៥០.២៧២.៧០៦ |

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សម្គាល់ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | ៩២២.៩៣២ | ៣.៧០៨.៣៤០ | ៣៨១.១០៨ | ១.៥៣៨.៥៣៣ |
| និយ័តកម្ម ៖ | | | | | |
| សំវិធានធនខាតការថយចុះតម្លៃ នៃឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន | ២២ | ២៤៤.៧៦៨ | ៩៨៣.៤៧៨ | ៦៦.៦២៦ | ២៦៨.៩៦៩ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | ១២៣.៤៩២ | ៤៩៦.១៩១ | ១២២.៦៣៦ | ៤៩៥.០៨២ |
| រំលស់ទ្រព្យសកម្មអរូបី | ១១ | ៣.២៤៦ | ១៣.០៤២ | ៤.៥៣៤ | ១៨.៣០៣ |
| កាតព្វកិច្ចអតីតភាពការងាររបស់បុគ្គលិក | | ៩២.០៦៧ | ៣៦៩.៩២៥ | - | - |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | (១៦.៦៣៣) | (៦៧.១៤៧) |
| ចំណូលការប្រាក់សុទ្ធ | | (២.៦០៨.០៧៤) | (១០.៤៧៩.២៤១) | (១.៦៧៣.៥៨១) | (៦.៧៥៦.២៤៦) |
| | | (១.២២១.៥៦៩) | (៤.៩០៨.២៦៥) | (១.១១៥.៣១០) | (៤.៥០២.៥០៦) |
| *បម្រែបម្រួលដើមទុនបង្វិល* | | | | | |
| ឥណទានអតិថិជន | ៧ | (៩.៩៤៦.៥៨៤) | (៣៩.៩៦៥.៣៧៥) | (២.៧៣៧.៥៤២) | (១១.០៥១.៤៥៧) |
| ទ្រព្យសកម្មផ្សេងៗ | | (១៣.៣២២) | (៥៣.៥២៨) | ២.៧២៧ | ១១.០០៩ |
| បំណុលផ្សេងៗ | | (៨១.០៣១) | (៣២៥.៥៨៣) | (៩.៣០៣) | (៣៧.៥៥៦) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងប្រតិបត្តិការ | | (១១.២៦២.៥០៦) | (៤៥.២៥២.៧៥១) | (៣.៨៥៩.៤២៨) | (១៥.៥៨០.៥១០) |
| | | | | | |
| ចំណូលការប្រាក់បានទទួល | | ២.៩៥២.៣២៦ | ១១.៨៦២.៤៤៦ | ១.៩៧១.២៩២ | ៧.៩៥៨.១០៥ |
| ចំណាយការប្រាក់បានបង់ | | (៤០១.៨០៩) | (១.៦១៤.៤៦៩) | (៣០៤.៨៧៧) | (១.២៣០.៧៨៩) |
| ពន្ធលើប្រាក់ចំណូលបានបង់ | ២៣ | (៩៦.៣៨១) | (៣៨៧.២៥៩) | (១១៦.៤៣០) | (៤៧០.០២៩) |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | (៨.៨០៨.៣៧០) | (៣៥.៣៩២.០៣៣) | (២.៣០៩.៤៤៣) | (៩.៣២៣.២២៣) |
| | | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ធានាដើមទុននៅធនាគារកណ្តាល | | (២៥០.០០០) | (១.០០៤.៥០០) | (១២៥.០០០) | (៥០៤.៦២៥) |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | (១៦២.៧៨៤) | (៦៥៤.០៦៦) | (៣៥៨.០០៦) | (១.៤៤៥.២៧០) |
| ការទិញទ្រព្យសកម្មអរូបី | ១១ | (១.៩៥៨) | (៧.៨៦៧) | (៥.០៤៦) | (២០.៣៧១) |
| សាច់ប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | ៥៧.៤៩៤ | ២៣២.១០៣ |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពវិនិយោគ** | | (៤១៤.៧៤២) | (១.៦៦៦.៤៣៣) | (៤៣០.៥៥៨) | (១.៧៣៨.១៦៣) |
| | | | | | |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីការបន្ថែមដើមទុន | | ៥.០០០.០០០ | ២០.០៩០.០០០ | ២.៥០០.០០០ | ១០.០៩២.៥០០ |
| សាច់ប្រាក់សុទ្ធបានពីកម្ចី | | ៥.១៧១.០០០ | ២០.៧៧៧.០៧៨ | ២.៤០៧.១០០ | ៩.៧១៧.៤៦៣ |
| សាច់ប្រាក់បង់កម្ចី | | (១.១៥៩.៨៧០) | (៤.៦៦០.៣៥៨) | (២.០១៦.៣៣២) | (៨.១៣៩.៩៣២) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | ៩.០១១.១៣០ | ៣៦.២០៦.៧២០ | ២.៨៩០.៧៦៨ | ១១.៦៧០.០៣១ |
| (**តំហយ**)/**កំណើនក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (២១១.៩៨២) | (៨៥១.៧៤៦) | ១៥០.៧៦៧ | ៦០៨.៦៤៥ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ៥៩៦.៨៧១ | ២.៤០៩.៥៦៧ | ៤៤៦.១០៤ | ១.៨០០.៩២២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១១.៣៣៧) | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ២៤ | ៣៨៤.៨៨៩ | ១.៥៤៦.៤៨៤ | ៥៩៦.៨៧១ | ២.៤០៩.៥៦៧ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

### ១. ព័ត៌មានទូទៅ

គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុសំរឹទ្ធិស័ក លីមីតធីត (ហៅកាត់ថា "ក្រុមហ៊ុន") បានចុះបញ្ជីពាណិជ្ជកម្មជា ក្រុមហ៊ុន មហាជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co-០៤៨៥ KH/២០១០ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ជាមួយក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ក្រុមហ៊ុនបានទទួលអាជ្ញា-ប័ណ្ណពីធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងសេវាផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ ដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅ ផ្ទះលេខ ៥០២G-៥០២H មហាវិថី ព្រះមុនីវង្ស សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាភិបាលបានអនុម័តរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩។

### ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងស្របទៅតាម គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS")។ ក្នុងការអនុវត្ត CAS ក្រុមហ៊ុនក៏បានអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា CIFRS 7 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ" ផងដែរ។ គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និង CAS តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងឆ្នាំដែលបានរាយការណ៍នេះ។ បើទោះជាការប៉ាន់ស្មានទាំងនេះ ផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ បម្រែបម្រួលស្តង់ដារគណនេយ្យថ្មី

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ហៅកាត់ថា "ក្រុមប្រឹក្សា ជាតិគណនេយ្យ") បានប្រកាសដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (ហៅកាត់ថា "IASB") រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗ។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំ របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬបន្ទាប់ពីនេះ។

យោងតាមសារាចរណែនាំលេខ ០៥៨ សហវ-កជគ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ក្រុមប្រឹក្សាជាតិគណនេយ្យបាន អនុម័តឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ឬបន្ទាប់ពីនេះ។

យោងតាមសារាចរណែនាំលេខ ០០៤ សហវ-កជគ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការដាក់ឱ្យប្រើប្រាស់ CIFRS សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។ សារាចរណែនាំបានពន្យល់ពីនិយមន័យ សហគ្រាសទទួលខុសត្រូវសាធារណៈ និងសហគ្រាសមិនទទួលខុសត្រូវសាធារណៈ។ សហគ្រាសទទួលខុសត្រូវសាធារណៈ តម្រូវឱ្យប្រើប្រាស់ CIFRS និងសហគ្រាសមិនទទួលខុសត្រូវសាធារណៈ តម្រូវឱ្យប្រើប្រាស់ CIFRS ឬ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម (ហៅកាត់ថា CIFRS for SMEs).

ក្រុមហ៊ុន គឺជាសហគ្រាសទទួលខុសត្រូវមិនមែនសាធារណៈ ដូច្នេះក្រុមហ៊ុនតម្រូវឱ្យប្រើប្រាស់ CIFRS ឬ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម (ហៅកាត់ថា CIFRS for SMEs) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

CAS ស្តង់ដារគណនេយ្យដែលកំពុងប្រើប្រាស់បច្ចុប្បន្ន មានភាពខុសប្លែកពី CIFRS តាមផ្នែកជាច្រើន។

ដូច្នេះការដាក់ឱ្យប្រើប្រាស់ CIFRS for SMEs នឹងមានផលប៉ះពាល់មួយចំនួនទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

### ២.៣ ការប្តូររូបិយប័ណ្ណ

#### (i) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយា-កាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ ប្រាក់ដុល្លារអាមេរិក ឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ និងធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍នានារបស់ក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។

#### (ii) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ដាក់បង្ហាញត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ២.៣ ការប្តូររូបិយប័ណ្ណ (ត)

### (iii) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៤ប្រ.ក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ របស់ធនាគារកណ្តាល តម្រូវឲ្យកត់ត្រាប្តូរទៅជាប្រាក់រៀលចំពោះតារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍ លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការ របស់ធនាគារកណ្តាលនាកាលបរិច្ឆេទរបាយការណ៍ ដែល១ដុល្លារអាមេរិកស្មើនឹង ៤.០១៨រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ៖ ១ដុល្លារអាមេរិកស្មើនឹង ៤.០៣៧រៀល)។ តួលេខដែលត្រូវបានប្តូរនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់បង្ហាញដូចតួលេខជាប្រាក់ដុល្លារអាមេរិកនោះទេ ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

## ២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់និងសាច់ប្រាក់សមមូលរួមមានសមតុល្យ ដែលមានកាលកំណត់ដើម បីខែ ឬតិចជាងបីខែ គិតចាប់ពីថ្ងៃទទួលបានសាច់ប្រាក់ ក្នុងនោះរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានកម្រិតនៅធនាគារកណ្តាល សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ។

## ២.៥ ឥណទានអតិថិជន

ឥណទានអតិថិជនទាំងអស់ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការ តាមចំនួនទឹកប្រាក់ដើម ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនជាក់លាក់ និងទូទៅសម្រាប់ឥណទានអាក្រក់ និងសង្ស័យ។
ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពប្រាកដថា នឹងអាចប្រមូលប្រាក់មកវិញបាន។ ការប្រមូលបានមកវិញពីឥណទានដែលជម្រះចេញពីបញ្ជី កាលពីគ្រាមុន ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

## ២.៦ សំវិធានធនហានិភ័យឥណទាន

ក្រុមហ៊ុនបានអនុវត្តការធ្វើចំណាត់ថ្នាក់សំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុ ដែលតម្រូវដោយប្រកាសរបស់ធនាគារកណ្តាលបានចេញប្រកាសលេខ ធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យ ឥណទាន និងសំវិធានធនលើអ៊ីមភែរមិន សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ"។ ឥណទាន និង បុរេប្រទាន ផលិតផលហិរញ្ញវត្ថុផ្សេងៗ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការ ត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រា សំវិធានធនអប្បបរមាអាស្រ័យទៅតាម ចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបាន ដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) លុះត្រាតែមានពត៌មានផ្សេងទៀតដែលចង្អុល បង្ហាញពីស្ថានភាព អាក្រក់ជាងនេះ។

## គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

### ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៦ សំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុ (ត)

សំវិធានធនឥណទាន និងបុរេប្រទាន ត្រូវបានបង្ហាញដោយការកាត់បន្ថយចំនួនទឹកប្រាក់ពីឥណទាន និងបុរេប្រទាន។

សំវិធានធនសមតុល្យ និងការដាក់ប្រាក់ក្នុងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ត្រូវបានបង្ហាញដោយការ កាត់បន្ថយចំនួនសមតុល្យ និងការដាក់ប្រាក់ក្នុងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ។

តារាងខាងក្រោមនេះបង្ហាញពីចំណាត់ថ្នាក់ឥណទាន និងសំវិធានធនអប្បបរមា៖

| **ប្រកាសថ្មីលេខ ធ៧-០១៧-៣៤៤ ប្រ.ក** | | | **ប្រកាសចាស់លេខ ធ៧-០២-១៨៦ ប្រ.ក** | | |
|---|---|---|---|---|---|
| **ចំណាត់ថ្នាក់ហ្វាស៊ីលីធី** | **ចំនួនថ្ងៃផុតកំណត់** | **សំវិធានធន** | **ចំណាត់ថ្នាក់ឥណទាន** | **ចំនួនថ្ងៃផុតកំណត់** | **សំវិធានធន** |
| រយៈពេលខ្លី | | | រយៈពេលខ្លី | | |
| សំវិធានធនទូទៅ: | | | សំវិធានធនទូទៅ: | | |
| ឥណទានធម្មតា | តិចជាង ១៥ ថ្ងៃ | ១% | ឥណទានធម្មតា | តិចជាង ៣០ ថ្ងៃ | 0% |
| សំវិធានធនជាក់លាក់: | | | សំវិធានធនជាក់លាក់: | | |
| ឥណទានឃ្លាំមើល | ១៥ ថ្ងៃ – ៣០ ថ្ងៃ | ៣% | ឥណទានក្រោមស្តង់ដារ | ៣១ ថ្ងៃ – ៦០ ថ្ងៃ | ១០% |
| ឥណទានក្រោមស្តង់ដារ | ៣១ ថ្ងៃ – ៦០ ថ្ងៃ | ២០% | ឥណទានសង្ស័យ | ៦១ ថ្ងៃ – ៩០ ថ្ងៃ | ៣០% |
| ឥណទានសង្ស័យ | ៦១ ថ្ងៃ – ៩០ ថ្ងៃ | ៥០% | ឥណទានបាត់បង់ | ៩០ ថ្ងៃ ឬលើស | ១០០% |
| ឥណទានបាត់បង់ | ៩១ ថ្ងៃ ឬលើស | ១០០% | | | |
| រយៈពេលវែង | | | រយៈពេលវែង | | |
| សំវិធានធនទូទៅ: | | | ឥណទានធម្មតា | តិចជាង ៣០ ថ្ងៃ | ៣% |
| ឥណទានធម្មតា | តិចជាង ៣០ ថ្ងៃ | ១% | សំវិធានធនជាក់លាក់: | | |
| សំវិធានធនជាក់លាក់: | | | ឥណទានក្រោមស្តង់ដារ | ៣១ ថ្ងៃ – ១៨០ ថ្ងៃ | ១០% |
| ឥណទានឃ្លាំមើល | ៣០ ថ្ងៃ – ៨៩ ថ្ងៃ | ៣% | ឥណទានសង្ស័យ | ១៨១ ថ្ងៃ – ៣៦០ ថ្ងៃ | ៣០% |
| ឥណទានក្រោមស្តង់ដារ | ៩០ ថ្ងៃ – ១៧៩ ថ្ងៃ | ២០% | ឥណទានបាត់បង់ | ៣៦០ ថ្ងៃ ឬលើស | ១០០% |
| ឥណទានសង្ស័យ | ១៨០ ថ្ងៃ – ៣៥៩ ថ្ងៃ | ៥០% | | | |
| ឥណទានបាត់បង់ | ៣៦០ ថ្ងៃ ឬលើស | ១០០% | | | |

ការផ្លាស់ប្តូរសំវិធានធនក្នុងអំឡុងឆ្នាំ ត្រូវបានអនុវត្តទៅតាមតម្រូវការនៃប្រកាសរបស់ធនាគារកណ្តាល ដូចនេះផលប៉ះពាល់នៃការផ្លាស់ប្តូរនេះ ត្រូវបានអនុវត្តទៅមុខ។ ប្រសិនបើក្រុមហ៊ុនអនុវត្តការផ្លាស់ប្តូរសំវិធានធនក្នុងឆ្នាំមុន សំវិធានធនបន្ថែមសម្រាប់ហ្វាស៊ីលីធីហិរញ្ញវត្ថុមានចំនួន ១៥៣.៦៧៧ ដុល្លារអាមេរិក គួរត្រូវបានកត់ត្រាក្នុងឆ្នាំមុន។

### ២.៧ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងការខាតបង្គរដែលបណ្តាលមកពីការ ថយចុះតម្លៃ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ដែលបានកើតឡើងក្នុងការនាំយកទ្រព្យសកម្មទាំងនោះមកកាន់ទីតាំង និងលក្ខខណ្ឌចាំបាច់ ដើម្បីឱ្យវាអាចបំពេញប្រតិបត្តិការទៅតាមការគ្រោងទុករបស់គណៈគ្រប់គ្រង។

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរ

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

ចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ តម្លៃយោងនៃទ្រព្យដែលត្រូវបានផ្លាស់ប្តូរ ត្រូវបានគេឈប់កត់ត្រា។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

ការធ្វើរំលស់ទៅលើទ្រព្យសកម្ម ត្រូវបានកត់ត្រាជាចំណាយតាមវិធីសាស្ត្ររំលស់សមតុល្យថយចុះ ដើម្បីបែងចែកថ្លៃដើមនៃទ្រព្យសកម្មដកតម្លៃសំណល់ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វា។ អាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មមានដូចខាងក្រោម ៖

| | អាយុកាលប្រើប្រាស់ | វិធីសាស្ត្ររំលស់ថេរ |
|---|---|---|
| កែលម្អទ្រព្យជួល | រយៈពេលខ្លីជាងគេរវាងកាលបរិច្ឆេទកិច្ចសន្យាជួលនិងអាយុកាលសេដ្ឋកិច្ច | សមតុល្យថយចុះ |
| យានយន្ត | ៤ ឆ្នាំ | សមតុល្យថយចុះ |
| បរិក្ខារការិយាល័យ | ៤ ឆ្នាំ | សមតុល្យថយចុះ |
| កុំព្យូទ័រ និង បរិក្ខារអេឡិចត្រូនិច | ២ ឆ្នាំ ទៅ ៥ ឆ្នាំ | សមតុល្យថយចុះ |
| គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ | ៤ ឆ្នាំ | សមតុល្យថយចុះ |
| ទ្រព្យសកម្មផ្សេងៗ | ៥ ឆ្នាំ | សមតុល្យថយចុះ |

តម្លៃសំណល់របស់ទ្រព្យសកម្ម និងអាយុកាលប្រើប្រាស់ ត្រូវបានត្រួតពិនិត្យ និងកែសម្រួលតាមការសមស្រប ប្រសិនបើមានសញ្ញាណណាមួយចង្អុលបង្ហាញឱ្យឃើញថាមានការប្រែប្រួលជាសារវន្ត ចាប់តាំងពីកាលបរិច្ឆេទរាយការណ៍មុនមក។

ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មណាមួយ មានចំនួនច្រើនជាងតម្លៃប៉ាន់ស្មានដែលអាចទទួលមកវិញបានវា នឹងត្រូវបានកត់ត្រាបន្ថយភ្លាម ឱ្យស្មើនឹងតម្លៃដែលអាចទទួលមកវិញបាន។

ចំណេញ និងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបរវាងលំហូរសាច់ប្រាក់ពីការលក់ជាមួយនឹងតម្លៃយោង និងចំណាយពាក់ព័ន្ធផ្សេងៗ ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

## ២.៨ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញនិងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ រំលស់ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីបែងចែកថ្លៃដើមលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វារយៈពេល៥ឆ្នាំ។

ចំណាយនានាពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៩ ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនមានកាលកំណត់ គឺមិនត្រូវបានធ្វើរំលស់ទេ ប៉ុន្តែត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានគេកត់ត្រាតាមចំនួនលម្អៀងរវាងតម្លៃនៅសល់នៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។ ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលទៅតាមទំហំតម្លៃយោងនៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃយោងដែលបានកំណត់ កាត់កងនឹងរំលស់ប្រសិនបើមិនបានកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

### ២.១០ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាត្រឹមថ្លៃដើម និងចំណាយជាបន្តបន្ទាប់គិតត្រឹមប្រាក់ដើម និងអត្រាការប្រាក់ដែលមិនទាន់បានទូទាត់។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១១ អត្ថប្រយោជន៍បុគ្គលិក

ការធ្វើវិសោធនកម្មស្តីពីច្បាប់ការងារ ចុះនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ និងប្រកាសលេខ ៤៤៣ MLVT/Br.k ចុះនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ហើយការទូទាត់ប្រាក់បំណាច់ត្រូវធ្វើជារៀងរាល់៦ខែម្តង នៅថ្ងៃទី៣០ ខែមិថុនា និងនៅថ្ងៃទី៣១ ខែធ្នូ សម្រាប់កិច្ចសន្យាការងារដែលមានថេរវេលាមិនកំណត់ (ហៅកាត់ថា"UDC")។ អត្ថប្រយោជន៍នេះ តម្រូវឱ្យក្រុមហ៊ុនធ្វើការទូទាត់អតីតភាពការងាររបស់បុគ្គលិករហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ សម្រាប់បុគ្គលិកដែលបានបម្រើការងារឱ្យក្រុមហ៊ុនមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅតែបន្តបម្រើការងារឱ្យក្រុមហ៊ុន។ ការទូទាត់ប្រាក់បំណាច់អតីតភាពការងារដល់បុគ្គលិក គឺអាស្រ័យលើអតីតភាពការងាររបស់បុគ្គលិក ហើយមិនត្រូវលើសពី៦ខែមធ្យមភាគនៃប្រាក់បៀវត្សរ៍គោលរបស់បុគ្គលិកឡើយ។ អតីតភាពការងាររបស់បុគ្គលិក ត្រូវបានទូទាត់ចំនួន៧,៥ថ្ងៃ ជារៀងរាល់៦ខែម្តង តាមការទូទាត់អតីតភាពការងារថ្មី។

បំណុលអតីតភាពការងារ ត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងការិយបរិច្ឆេទរាយការណ៍។ តម្លៃបច្ចុប្បន្ននៃការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ត្រូវបានកំណត់ដោយអប្បហារនៃចំណាយត្រូវបង់ប៉ាន់ស្មាននាពេលអនាគត ដោយយោងតាមទៅអត្រាការប្រាក់ទីផ្សារបច្ចុប្បន្ន នៃសាជីវកម្មនោះ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១២ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ដោយវាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។ សំវិធានធនត្រូវបានកត់ត្រាទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយនៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងអំពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុតត្រូវបានកត់ត្រាជាចំណាយការប្រាក់។

### ២.១៣ ការកត់ត្រាចំណូលការប្រាក់ និង ចំណាយការប្រាក់

ចំណូលការប្រាក់បានមកពីឥណទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានអតិថិជនក្លាយជាឥណទានមិនដំណើរការ ការកត់ត្រាចំណូលការប្រាក់ពីឥណទានអតិថិជន ត្រូវបានព្យួរទុកមួយរយៈរហូតដល់ពេលដែលទទួលបានសាច់ប្រាក់ជាក់ស្តែង។

ចំណាយការប្រាក់ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

### ២.១៤ ចំណូលកម្រៃ និងជើងសា

ចំណូលកម្រៃ និងជើងសា ត្រូវបានបង្ហាញជាចំណូលឥណទាន និងចំណូលរដ្ឋបាលដែលត្រូវបានកត់ត្រាជាចំណូលនៅពេលដែលឥណទានបានកើតឡើង។ ចំណូលកម្រៃ និងជើងសា រួមមាន ចំណូលប្រតិបត្តិការ ដែលត្រូវទូទាត់រៀងរាល់ខែនៅពេលដែលអតិថិជនបានបង់ការប្រាក់ជូនក្រុមហ៊ុន។

### ២.១៥ ភតិសន្យាប្រតិបត្តិ

ភតិសន្យាដែលហានិភ័យមួយផ្នែកធំ និងផលនៃកម្មសិទ្ធិលើទ្រព្យសកម្មនេះ ត្រូវបានរក្សាដោយភាគីម្ចាស់ទ្រព្យ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ (ការលើកទឹកចិត្តសុទ្ធ ដែលទទួលបានពីម្ចាស់ទ្រព្យ) ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរអាស្រ័យទៅតាមរយៈពេលនៃភតិសន្យានោះ។

### ២.១៦ ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំនិងពន្ធពន្យារលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបាន អនុម័តរួចមួយផ្នែកធំគិតត្រឹមកាលបរិច្ឆេទរាយការណ៍ នៅក្នុងប្រទេសដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានធ្វើសំវិធានធនដោយប្រើវិធីសាស្ត្របំណុលលើលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្មនិងបំណុលសម្រាប់ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងចំនួនដែលត្រូវបានប្រើប្រាស់សម្រាប់គោលដៅ

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

ពន្ធដារ។ ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងត្រូវអនុវត្តចំពោះលម្អៀងបណ្ដោះអាសន្ន នៅពេលដែលវាកត់ត្រាត្រលប់មកវិញ ដោយផ្អែកលើច្បាប់ដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួច ឬជាគោលគិតត្រឹមកាលបរិច្ឆេទរាយការណ៍។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងបំណុលពន្ធក្នុងឆ្នាំជាមួយនឹងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតសម្រាប់យកលម្អៀងបណ្ដោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយ-ការណ៍នីមួយៗ ហើយត្រូវបានកាត់បន្ថយទៅតាមទំហំដែលទំនងជាមិនមានប្រាក់ចំណេញជាប់ពន្ធត្រូវបានកត់ត្រា។

## ២.១៧ ភាគីពាក់ព័ន្ធ

ភាគីដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធ ប្រសិនបើភាគីនោះមានលទ្ធភាពដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដីក្នុងការគ្រប់គ្រងភាគីមួយផ្សេងទៀត ឬមានឥទ្ធិពលជាសារវន្តលើភាគីមួយផ្សេងទៀតក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការនិងហិរញ្ញវត្ថុ ឬប្រសិនបើក្រុមហ៊ុននិងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬស្ថិតនៅក្រោមឥទ្ធិពលរួមរបស់ក្រុមហ៊ុនមេតែមួយ។ ភាគីពាក់ព័ន្ធអាចជាឯកបុគ្គលឬជាក្រុមហ៊ុន រាប់ទាំងសមាជិកគ្រួសារជិតដិតរបស់បុគ្គលនោះក៏ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធដែរ។

អនុលោមតាមច្បាប់ស្ដីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានឲ្យនិយមន័យថាជាភាគីទាំងឡាយណាដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោល យ៉ាងហោចណាស់១០%នៃដើមទុនរបស់ក្រុមហ៊ុន ឬមានសិទ្ធិបោះឆ្នោត រួមទាំងឯកបុគ្គលដែលមានតួនាទីក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬ ការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន។

## ៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាននិងការសន្មតដែលប៉ះពាល់ដល់ចំនួនទ្រព្យសកម្មនិងបំណុលដែលបានរាយការណ៍។ ការប៉ាន់ស្មាននិងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ដោយផ្អែកតាមបទពិសោធន៍ក្នុងគ្រាមុននិងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកអំពីព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាវាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។

### (ក) ការខាតបង់លើការថយចុះតម្លៃនៃហ្វាស៊ីលីធីហិរញ្ញវត្ថុ

ក្រុមហ៊ុនអនុវត្តតាមការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធីហិរញ្ញវត្ថុ ដែលតម្រូវដោយប្រកាសរបស់ធនាគារកណ្ដាលលេខធ៧-០១៧-៣៤៤ប្រ.ក. ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ"។ ឥណទាន និងបុរេប្រទាន ផលិតផលហិរញ្ញវត្ថុផ្សេងៗ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការ ត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រាសំវិធានធនអប្បបរមាអាស្រ័យទៅតាមចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់)។ ក្រុមប្រឹក្សាភិបាលជឿជាក់ថា អាយុកាលឥណទាន (តាមថ្ងៃកំណត់) គឺជាមូលដ្ឋានដើម្បីកំណត់ចំណាត់ថ្នាក់ឥណទាន គឺសមស្របដើម្បីកំណត់ឱនភាពនៃការខាតបង់លើការថយចុះតម្លៃហ្វាស៊ីលីធីហិរញ្ញវត្ថុដូចបានអនុវត្តតាមប្រកាសនេះ។

**៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)**

**(ខ) កាតព្វកិច្ចអតីតភាពការងាររបស់បុគ្គលិក**

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអតីតភាពការងាររបស់បុគ្គលិក គឺផ្អែកលើតក្តាមួយចំនួនដែលបានកំណត់លើមូលដ្ឋានដោយប្រើប្រាស់ការប៉ាន់ស្មានមួយចំនួន។ ការប៉ាន់ស្មានដោយប្រើប្រាស់ការកំណត់ថ្លៃដើមសម្រាប់កាតព្វកិច្ចអតីតភាពការងាររបស់បុគ្គលិក រួមមានការផ្លាស់ប្តូរបុគ្គលិក និងអត្រាអប្បហារ។ បម្រែបម្រួលនៃការប៉ាន់ស្មាននេះនឹងប៉ះពាល់ដល់តម្លៃយោងនៃកាតព្វកិច្ចអតីតភាពការងាររបស់បុគ្គលិក។

**(គ) ពន្ធ**

ពន្ធ ត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ដែលបានអនុម័តរួចជាស្ថាពរ នាកាលបរិច្ឆេទរាយការណ៍។ គណៈគ្រប់គ្រងធ្វើការវាយតម្លៃជាប្រចាំ អំពីស្ថានភាពដែលកើតឡើងក្នុងលិខិតប្រកាសពន្ធទាក់ទិនទៅនឹងបទប្បញ្ញត្តិពន្ធ និងបំណកស្រាយរបស់វាដែលនៅជាធរមាន។ សំវិធានធនត្រូវបានកត់ត្រាតាមការសមស្រប ទៅតាមមូលដ្ឋាននៃចំនួនទឹកប្រាក់ដែលរំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយលើបំណុលពន្ធនឹងធ្វើឡើងបន្ទាប់ពីអធិការកិច្ចរបស់អាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយ មានភាពខុសគ្នាពីចំនួនប្រាក់ពន្ធដែលបានកត់ត្រាដំបូង លម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់លើបំណុលពន្ធ និងសមតុល្យរបស់វា នៅក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធត្រូវបានធ្វើឡើង។

**គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ៤. សាច់ប្រាក់ក្នុងដៃ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| សាច់ប្រាក់ក្នុងដៃ | ១០៨.៦៧៤ | ៤៣៦.៦៥៣ | ១៧១.១៤៨ | ៦៩០.៥២៤ |
| | ១០៨.៦៧៤ | ៤៣៦.៦៥៣ | ១៧១.១៤៨ | ៦៩០.៥២៤ |

សាច់ប្រាក់ខាងលើ ត្រូវបានត្រួតពិនិត្យតាមអត្រារូបិយប័ណ្ណដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ប្រាក់ដុល្លាអាមេរិក | ១០៥.២១៩ | ៤២២.៧៧០ | ១៧១.១៤៨ | ៦៩០.៥២៤ |
| ប្រាក់រៀល | ៣.៤៥៥ | ១៣.៨៨៣ | - | - |
| | ១០៨.៦៧៤ | ៤៣៦.៦៥៣ | ១៧១.១៤៨ | ៦៩០.៥២៤ |

## ៥. សាច់ប្រាក់ជាមួយភ្នាក់ងារ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| Wing (Cambodia) Limited Specialised Bank | ១១.៦០២ | ៤៦.៦១៧ | ៧.៥៧៨ | ៣០.៥៩២ |
| Asia Wei Luy Co.,Ltd | ៨០.៨២៤ | ៣២៤.៧៥១ | ៩៦.៣៣១ | ៣៨៨.៨៨៨ |
| Asia Cash Express Plc. | ៧១.៧៦៥ | ២៨៨.៣៥១ | ៣.៩៧៣ | ១៦.០៣៩ |
| | ១៦៤.១៩១ | ៦៥៩.៧១៩ | ១០៧.៨៨២ | ៤៣៥.៥១៩ |

## ៦. សមតុល្យនៅធនាគារកណ្តាល

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ប្រាក់តម្កល់ដើមទុន | ៥០០.០០០ | ២.០០៩.០០០ | ២៥០.០០០ | ១.០០៩.២៥០ |
| គណនីចរន្ត | ២.៧៩៦ | ១១.២៣៤ | ១.៤៧១ | ៥.៩៣៨ |
| | ៥០២.៧៩៦ | ២.០២០.២៣៤ | ២៥១.៤៧១ | ១.០១៥.១៨៨ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

### (ក) ប្រាក់តម្កល់ដើមទុន

យោងតាមប្រកាសលេខ ធ៧-០៦-២០៩ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីអាជ្ញាប័ណ្ណគ្រឹះស្ថានហិរញ្ញវត្ថុ ក្រុមហ៊ុនត្រូវបានតម្រូវឱ្យតម្កល់ដើមទុននៅធនាគារកណ្តាលចំនួន ៥% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះនឹងបង្វិលជូនក្រុមហ៊ុនវិញនៅពេលដែលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់អាជីវកម្មរបស់ខ្លួន។

### (ខ) អត្រាការប្រាក់

ប្រាក់តម្កល់ដើមទុនជាប្រាក់ដុល្លារអាមេរិកទទួលបានការប្រាក់ ០,៦២%ក្នុងមួយឆ្នាំ (២០១៧៖០,៣៦ ក្នុងមួយឆ្នាំ)។ ការបង់ការប្រាក់ត្រូវធ្វើជារៀងរាល់៦ខែម្តង។

## ៧. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

### (ក) តាមប្រភេទអាជីវកម្ម

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | ១០៩៧២៨. | ៤៣៨៨៧៨. | ៣១៦៣៧០. | ១២៧៧.១៨៦. |
| ដកៈ សំវិធានធន | (១(២០៣. | (៤(៨៣៤. | - | - |
| | ១០៨០២៥. | ៤៣៤០៤៤. | ៣១៦៣៧០. | ១២៧៧.១៨៦. |

### (ខ) តាមធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| Canadia Bank Plc | ៨០.៥៥៨ | ៣២៣.៦៨២ | ៣៩.៧៥៦ | ១៦០.៤៩៥ |
| PRASAC Microfinance Institution Limited | ១២.៣២៧ | ៤៩.៥៣០ | ៤៧.៣៩៤ | ១៩១.៣៣០ |
| Hattha Kaksekar Limited | ៨.២៤៨ | ៣៣.១៤០ | ២១០.០២២ | ៨៤៧.៨៥៩ |
| RHB Indochina Bank Limited | ២.៣១៣ | ៩.២៩៤ | ១៧.១៥០ | ៦៩.២៣៥ |
| ACLEDA Bank Plc | ២.០១៣ | ៨.០៨៨ | - | - |
| SHB Plc Phnom Penh Branch | ១.៦៩៩ | ៦.៨២៧ | ១.៣៩០ | ៥.៦១១ |
| Phnom Penh Commercial Bank Plc | ៩៧៧ | ៣.៩២៦ | - | - |
| Advanced Bank of Asia Limited | ៦៧៨ | ២.៧២៤ | ៦៥៨ | ២.៦៥៦ |
| Amret Plc. | ៤១៥ | ១.៦៦៧ | - | - |
| | ១០៩.២២៨ | ៤៣៨.៨៧៨ | ៣១៦.៣៧០ | ១.២៧៧.១៨៦ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ៨. ឥណទានអតិថិជន

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានឯកត្តជន | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |
| | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យ៖ | | | | |
| សំវិធានធនជាក់លាក់ | (២៣១.៦៨៣) | (៩៣០.៩០២) | (៩១.១០៣) | (៣៦៧.៧៨៣) |
| សំវិធានធនទូទៅ | (២៨.៦០៤) | (១១៤.៩៣១) | - | - |
| | (២៦០.២៨៧) | (១.០៤៥.៨៣៣) | (៩១.១០៣) | (៣៦៧.៧៨៣) |
| | ២៣.០២២.៤២៧ | ៩២.៥០៤.១១២ | ១៣.៣១៩.៤០៨ | ៥៣.៧៧០.៤៥០ |

## (ក) សំវិធានធនឥណទានអាក្រក់ និងសង្ស័យ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាដើមឆ្នាំ | ៩១.១០៣ | ៣៦៧.៧៨៣ | ៣៥.៨៥៥ | ១៤៤.៧៤៧ |
| សំវិធានធនក្នុងឆ្នាំ | ២៤៣.៥៦៥ | ៩៧៨.៦៤៤ | ៦៦.៦២៦ | ២៦៨.៩៦៩ |
| ការជម្រះចេញពីបញ្ជី | (៧៤.៣៨១) | (៣០០.៥៩៤) | (១១.៣៧៨) | (៤៥.៩៣៣) |
| នាដំណាច់ឆ្នាំ | ២៦០.២៨៧ | ១.០៤៥.៨៣៣ | ៩១.១០៣ | ៣៦៧.៧៨៣ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

ឥណទានអតិថិជនមានដូចខាងក្រោម៖

**(ខ) វិភាគតាមចំណាត់ថ្នាក់ឥណទាន**

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានស្តង់ដារ៖ | | | | |
| មានការធានា | ២២.០៨៣.០០១ | ៨៨.៧២៩.៤៩៨ | ១១.៧២៨.៩៨៤ | ៤៧.៣៤៩.៩០៨ |
| មិនមានការធានា | ១.០៨៥.២៧៦ | ៤.៣៦០.៦៣៩ | ១.៤៧១.៧៦៨ | ៥.៩៤១.៥២៧ |
| ឥណទានឃ្លាំមើល៖ | | | | |
| មានការធានា | ៣២.៤២៦ | ១៣០.២៨៨ | - | - |
| មិនមានការធានា | ៥.៦៦២ | ២២.៧៥០ | - | - |
| ឥណទានក្រោមស្តង់ដារ៖ | | | | |
| មានការធានា | ៣៩.០៤៥ | ១៥៦.៨៨៣ | ៦៦.៨៤០ | ២៦៩.៨៣៣ |
| មិនមានការធានា | ២.១៨៥ | ៨.៧៧៩ | ៤.៥៦៤ | ១៨.៤២៥ |
| ឥណទានសង្ស័យ៖ | | | | |
| មានការធានា | ២០.០៦៨ | ៨០.៦៣៣ | ៦៨.១៦១ | ២៧៥.១៦៦ |
| មិនមានការធានា | ១១.៧៤១ | ៤៧.១៧៥ | ៩.៥៤២ | ៣៨.៥២១ |
| ឥណទានបាត់បង់៖ | | | | |
| មានការធានា | ១.៣៧១ | ៥.៥០៩ | ៤៤.៦៧៥ | ១៨០.៣៥៣ |
| មិនមានការធានា | ១.៩៣៩ | ៧.៧៩១ | ១៥.៩៧៧ | ៦៤.៥០០ |
| | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |

**(គ) វិភាគឥណទានតាមកាលកំណត់**

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ដល់កាលកំណត់សងក្នុងរយៈពេល១ឆ្នាំ | ៦៤២.៧៣៧ | ២.៥៨២.៥១៧ | ៤១៣.៩២៣ | ១.៦៧១.០០៧ |
| ពី១ឆ្នាំ ទៅ ៥ឆ្នាំ | ១១.៧១៦.៦១៩ | ៤៧.០៧៧.៣៧៥ | ១២.០១៧.៦១៤ | ៤៨.៥១៥.១០៨ |
| លើសពី៥ឆ្នាំ | ១០.៩២៣.៣៥៨ | ៤៣.៨៩០.០៥៣ | ៩៧៨.៩៧៤ | ៣.៩៥២.១១៨ |
| | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

### ៨. ឥណទានអតិថិជន(ត)

### (ឃ) វិភាគតាមប្រភេទអាជីវកម្ម

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| លំនៅដ្ឋាន/គ្រួសារ | ១៥.១៣៥.២៦៦ | ៦០.៨១៣.៤៩៩ | ៨.៤៧៣.៦៤៥ | ៣៤.២០៨.១០៥ |
| ជំនួញ និងពាណិជ្ជកម្មលក់រាយ | ៤.៩៤៤.៣៩៩ | ១៩.៨៦៨.២០២ | ៣.៦០៧.៩៥០ | ១៤.៥៦៥.២៩៤ |
| សេវាកម្ម | ១.៤៨៦.៤៩៦ | ៥.៩៧២.៧៤១ | ៥៦១.៤២០ | ២.២៦៦.៤៥៣ |
| កសិកម្ម | ៤៤៩.៣៥២ | ១.៨០៧.១០៤ | ១៧៧.៥១៣ | ៧១៦.៦២០ |
| សាងសង់ | ២១៨.៨២៥ | ៨៧៩.២៣៩ | ២២៧.៣៨២ | ៩១៩.៥៥៦ |
| ការធ្វើដំណើរ | ៧៩.០៩៥ | ៣១៧.៨០៤ | ៣៩.៧២៧ | ១៦០.៣៧៨ |
| តាមប្រភេទផ្សេងៗ | ៩៦៨.៤៨១ | ៣.៨៩១.៣៥៦ | ៣២២.៤៧៤ | ១.៣០១.៨២៧ |
| | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |

### (ង) វិភាគតាមទំនាក់ទំនង

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| អតិថិជនខាងក្រៅ | ២២.៨២២.៩១០ | ៩១.៧០២.៤៥២ | ១៣.២៩១.៥៣២ | ៥៣.៦៥៧.៩១៥ |
| បុគ្គលិក | ៤៥៩.៨០៤ | ១.៨៤៧.៤៩៣ | ១១៨.៩៧៩ | ៤៨០.៣១៨ |
| | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |

### (ច) វិភាគតាមទីកន្លែង

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទីក្រុងភ្នំពេញ | ៩.៧៤០.២៨៤ | ៣៩.១៣៦.៤៦១ | ៧.៥៣៣.៣០៧ | ៣០.៤១១.៩៦០ |
| ខេត្តកំពង់ស្ពឺ | ២.៣៧២.៤១៥ | ៩.៥៣២.៣៦៣ | ៨៥.៦៧២ | ៣៤៥.៨៥៨ |
| ខេត្តកណ្តាល | ៣.៩៥១.២២៦ | ១៥.៨៧៦.០២៦ | ៣.៤១២.៣២៩ | ១៣.៧៧៥.៥៧២ |
| ខេត្តបាត់ដំបង | ២.៩៣៥.៣៩២ | ១១.៧៩៤.៤០៥ | ៤៩៤.៤៣៦ | ១.៩៩៦.០៣៨ |
| ខេត្តតាកែវ | ៤.១៧៥.៤០៩ | ១៦.៧៧៦.៧៩៣ | ១.៧៩៥.០១០ | ៧.២៤៦.៤៥៥ |
| ខេត្តស្វាយរៀង | ៧០.៨៤៦ | ២៨៤.៦៥៩ | ៥៩.៧៥៧ | ២៤១.២៤០ |
| ខេត្តកំពត | ៣៧.១៤២ | ១៤៩.២៣៨ | ៣០.០០០ | ១២១.១១០ |
| | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

### ៨. ឥណទានអតិថិជន(ត)

### (ឆ) វិភាគតាមអត្រាការប្រាក់

អត្រាការប្រាក់ប្រចាំឆ្នាំមានដូចខាងក្រោម៖

| | ២០១៨ | ២០១៧ |
|---|---|---|
| ឥណទានអតិថិជនខាងក្រៅ | ៣% - ១៨% | ៣% - ៣៦% |
| ឥណទានបុគ្គលិក | 0% - ១៤,៤% | 0% - ១៤,៤% |

### (ជ) វិភាគតាមរូបិយប័ណ្ណ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ដុល្លាអាមេរិក | ២២.៥២១.៥១១ | ៩០.៤៩១.៤៣១ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |
| ប្រាក់រៀល | ៧៦១.២០៣ | ៣.០៥៨.៥១៤ | - | - |
| | ២៣.២៨២.៧១៤ | ៩៣.៥៤៩.៩៤៥ | ១៣.៤១០.៥១១ | ៥៤.១៣៨.២៣៣ |

### ៩. ទ្រព្យសកម្មផ្សេងៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការប្រាក់បង្គរត្រូវទទួល | ១៩៩.៣០៧ | ៨០០.៨១៦ | ១០៩.០២៧ | ៤៤០.១៤២ |
| ការដាក់ប្រាក់ | ១៤.៨០០ | ៥៩.៤៦៦ | ១៤.០០០ | ៥៦.៥១៨ |
| ការបង់ទុកមុន | ១០.១៣៥ | ៤០.៧២២ | ១.០៩៨ | ៤.៤៣៣ |
| ប្រាក់ដែលត្រូវទទួលផ្សេងៗ | ២៦.០២០ | ១០៤.៥៤៩ | ២២.៥៣៥ | ៩០.៩៧៣ |
| | ២៥០.២៦២ | ១.០០៥.៥៥៣ | ១៤៦.៦៦០ | ៥៩២.០៦៦ |

ទ្រព្យសកម្មផ្សេងៗទាំងអស់ ត្រូវបានរំពឹងថានឹងប្រមូលមកវិញបានក្នុងរយៈពេលមួយឆ្នាំ បន្ទាប់កាលបរិច្ឆេទតារាងតុល្យការ លើកលែងតែប្រាក់តម្កល់។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

### ១០. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ការកែលម្អទ្រព្យជួល ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារការិយាល័យ ដុល្លារអាមេរិក | កុំព្យូទ័រ និងបរិក្ខារបច្ចេកវិទ្យាព័ត៌មានវិទ្យា ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និង បរិក្ខារបំពាក់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | | |
| ថ្លៃដើម | ២១៥.៩១១ | ២១៩.៤៥៥ | ៦៥.៣៣៥ | ៨៩.២៣៥ | ៣៦.៦៥០ | ៦២៦.៥៨៦ |
| រំលស់បង្គរ | (៣០.៥៩៨) | (៧០.៩៨៧) | (២១.៩១៧) | (៥១.១០៩) | (១២.១២៧) | (១៨៦.៧៣៨) |
| **តម្លៃចុះបញ្ជីសុទ្ធ** | ១៨៥.៣១៣ | ១៤៨.៤៦៨ | ៤៣.៤១៨ | ៣៨.១២៦ | ២៤.៥២៣ | ៤៣៩.៨៤៨ |
| **គិតជាពាន់រៀល** | ៧៤៨.១០៩ | ៥៩៩.៣៦៥ | ១៧៥.២៧៨ | ១៥៣.៩១៥ | ៩៨.៩៩៩ | ១.៧៧៥.៦៦៦ |
| | | | | | | |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | |
| **នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨** | ១៨៥.៣១២ | ១៤៨.៤៦៨ | ៤៣.៤១៧ | ៣៨.១២៦ | ២៤.៥២៥ | ៤៣៩.៨៤៨ |
| ទិញបន្ថែម | ៤៤.៩៨១ | ៦៤.២២៥ | ១០.៥៨៧ | ៣៥.៣៦១ | ៧.៦៣០ | ១៦២.៧៨៤ |
| រំលស់ | (១០.៨៨៣) | (៥៣.១៧៤) | (១៤.២៣៥) | (៣៦.៤៦៥) | (៨.៧៣៥) | (១២៣.៤៩២) |
| **តម្លៃចុះបញ្ជីសុទ្ធចុងគ្រា** | ២១៩.៤១០ | ១៥៩.៥១៩ | ៣៩.៧៦៩ | ៣៧.០២២ | ២៣.៤២០ | ៤៧៩.១៤០ |
| | | | | | | |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | |
| ថ្លៃដើម | ២៦០.៨៩២ | ២៨៣.៦៨០ | ៧៥.៩២២ | ១២៦.៦៦០ | ៤៤.២៨២ | ៧៩១.៤៣៦ |
| រំលស់បង្គរ | (៤១.៤៨២) | (១២៤.១៦១) | (៣៦.១៥៣) | (៨៩.៦៣៩) | (២០.៨៦២) | (៣១២.២៩៧) |
| **តម្លៃចុះបញ្ជីសុទ្ធ** | ២១៩.៤១០ | ១៥៩.៥១៩ | ៣៩.៧៦៩ | ៣៧.០២១ | ២៣.៤២០ | ៤៧៩.១៣៩ |
| **គិតជាពាន់រៀល** | ៨៨១.៥៨៩ | ៦៤០.៩៤៧ | ១៥៩.៧៩២ | ១៤៨.៧៥០ | ៩៤.១០៣ | ១.៩២៥.១៨១ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ១១. ទ្រព្យសកម្មអរូបី

| | កម្មវិធីកុំព្យូទ័រ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | |
| ថ្លៃដើម | ១៣.០៩១ | ១៣.០៩១ |
| រំលស់បង្គរ | (៨.៥៥៧) | (៨.៥៥៧) |
| តម្លៃចុះបញ្ជីសុទ្ធ | ៤.៥៣៤ | ៤.៥៣៤ |
| **គិតជាពាន់រៀល** | ១៨.៣០៤ | ១៨.៣០៤ |
| | | |
| **គិតត្រឹមថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៨** | | |
| **នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨** | ៤.៥៣៤ | ៤.៥៣៤ |
| ទិញបន្ថែម | ១.៩៥៨ | ១.៩៥៨ |
| រំលស់ | (៣.២៤៦) | (៣.២៤៦) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៣.២៤៦ | ៣.២៤៦ |
| | | |
| **នៅថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៨** | | |
| ថ្លៃដើម | ១៥.០៤៩ | ១៥.០៤៩ |
| រំលស់បង្គរ | (១១.៨០៣) | (១១.៨០៣) |
| តម្លៃចុះបញ្ជីសុទ្ធ | ៣.២៤៦ | ៣.២៤៦ |
| **គិតជាពាន់រៀល** | ១៣.០៤២ | ១៣.០៤២ |

## ១២. កម្ចី

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កម្ចីពីភាគីមិនពាក់ព័ន្ធ(*) | ១.៥៦៥.១៥៦ | ៦.២៨៨.៧៩៧ | ៧៥១.៩២៦ | ៣.០៣៥.៥២៥ |
| កម្ចីពីភាគីពាក់ព័ន្ធ | ១០.១៣២.៤០០ | ៤០.៧១១.៩៨៣ | ៦.៩៣៤.៥០០ | ២៧.៩៩៤.៥៧៧ |
| | ១១.៦៩៧.៥៥៦ | ៤៧.០០០.៧៨០ | ៧.៦៨៦.៤២៦ | ៣១.០៣០.១០២ |

(*) កម្ចីនេះបានមកពីធនាគារ និងឯកត្តបុគ្គលដែលមានកាលកំណត់ពី១ឆ្នាំ ទៅ៧ឆ្នាំ ដោយមិនមានការធានា និងមានអត្រាការប្រាក់ពី៣% ទៅ១០%ក្នុងមួយឆ្នាំ។

## ១២. កម្ចី (ត)

### ក) តាមកាលហួសកំណត់

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់កម្ចីរយៈពេលខ្លី | ៤.៥២៤.៣១២ | ១៨.១៧៨.៦៨៦ | ១.៩៨២.៩៦៤ | ៨.០០៥.២២៦ |
| ប្រាក់កម្ចីរយៈពេលវែង | ៧.១៧៣.២៤៤ | ២៨.៨២២.០៩៤ | ៥.៧០៣.៤៦២ | ២៣.០២៤.៨៧៦ |
| | ១១.៦៩៧.៥៥៦ | ៤៧.០០០.៧៨០ | ៧.៦៨៦.៤២៦ | ៣១.០៣០.១០២ |

### ខ) តាមរូបិយប័ណ្ណ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ដុល្លារអាមេរិក | ១០.៩៩៨.៦៤៤ | ៤៤.១៩២.៥៥២ | ៧.៦៨៦.៤២៦ | ៣១.០៣០.១០២ |
| ប្រាក់រៀល | ៦៩៨.៩១២ | ២.៨០៨.២២៨ | - | - |
| | ១១.៦៩៧.៥៥៦ | ៤៧.០០០.៧៨០ | ៧.៦៨៦.៤២៦ | ៣១.០៣០.១០២ |

## ១៣. បំណុលផ្សេងៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| បង្គរការប្រាក់ត្រូវបង់ | ៤១.៧៤៣ | ១៦៧.៧២៣ | ១៧.៧៦៦ | ៧១.៧២១ |
| ពន្ធត្រូវបង់ផ្សេងៗ | ២៣.៨៦៨ | ៩៥.៩០២ | ១៣.៧៨៣ | ៥៥.៦៤២ |
| បង្គរប្រាក់រង្វាន់បុគ្គលិក | ១៦.០០៩ | ៦៤.៣២៤ | ១៣៣.៦១៧ | ៥៣៩.៤១២ |
| បង្គរកម្រៃវិជ្ជាជីវៈ | ១៥.៤០០ | ៦១.៨៧៧ | ៩.០២០ | ៣៦.៤១៤ |
| ចំណាយបង្គរផ្សេងៗ | ៧៧.៣៧៧ | ៣១០.៩០១ | ៤៩.២៦៨ | ១៩៨.៨៩៥ |
| ផ្សេងៗ | ៧៤៨ | ៣.០០៦ | - | - |
| | ១៧៥.១៤៥ | ៧០៣.៧៣៣ | ២២៣.៤៥៤ | ៩០២.០៨៤ |

បំណុលនេះ ត្រូវបានរំពឹងទុកថានឹងទូទាត់រួចក្នុងរយៈពេលមួយឆ្នាំពីទិន្នន័យតារាងតុល្យការ។

## ១៤. ភាគពួកិច្ចអតីតភាពការងាររបស់បុគ្គលិក

កាតព្វកិច្ចអតីតភាពការងាររបស់បុគ្គលិក មានចំនួន ៩២.០៦៧ ដុល្លារអាមេរិក ត្រូវបានបង្គរគិតត្រឹមថ្ងៃ ទី៣១ ខែធ្នូ ឆ្នាំ២០១៨ ស្របតាមច្បាប់ការងារ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ហើយប្រកាសថ្មីចុះនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ពីក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ។

## ១៥. ដើមទុន

ដើមទុនចុះបញ្ជីដំបូងរបស់ក្រុមហ៊ុនមានចំនួន១០០.០០០ភាគហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដែលតម្លៃចារឹក ១០០ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ ហើយភាគហ៊ុនទាំងអស់ត្រូវបានចេញផ្សាយ និងបង់រួចរាល់ជាស្ថាពរ។

| | ចំនួនភាគហ៊ុន | ដើមទុន ដុល្លារអាមេរិក | % នៃភាគហ៊ុន | ចំនួនភាគហ៊ុន | ដើមទុន ដុល្លារអាមេរិក | % នៃភាគហ៊ុន |
|---|---|---|---|---|---|---|
| **ម្ចាស់ភាគហ៊ុន** | | | | | | |
| លោក តាំង ងួន | ៧៧.០០០ | ៧.៧០០.០០០ | ៧៧% | ២៧.០០០ | ២.៧០០.០០០ | ៥៤% |
| លោក តាំង ហុង | ១៦.៥០០ | ១.៦៥០.០០០ | ១៧% | ១៦.៥០០ | ១.៦៥០.០០០ | ៣៣% |
| លោក ជាវ ស៊ីវណ្ណលាង | ៥.៥០០ | ៥៥០.០០០ | ៦% | ៥.៥០០ | ៥៥០.០០០ | ១១% |
| លោក ហ៊ិន ស៊ីចាវ | ៥០០ | ៥០.០០០ | ១% | ៥០០ | ៥០.០០០ | ១% |
| លោក ភួង ធីទៀង | ៥០០ | ៥០.០០០ | ១% | ៥០០ | ៥០.០០០ | ១% |
| | ១០០.០០០ | ១០.០០០.០០០ | ១០០% | ៥០.០០០ | ៥.០០០.០០០ | ១០០% |
| គិតជាពាន់រៀល | | ៤០.១៨០.០០០ | | | ២០.១៨៥.០០០ | |

ក្នុងអំឡុងឆ្នាំ ក្រុមហ៊ុនបានបង្កើនដើមទុនរបស់ខ្លួនពី ៥០.០០០ ភាគហ៊ុន ទៅ ១០០.០០០ ភាគហ៊ុន ។ លក្ខន្តិកៈដែលត្រូវបានធ្វើវិសោធនកម្ម ចំពោះការផ្លាស់ប្តូរដើមទុនចុះបញ្ជីរហូតដល់ចំនួន១០.០០០.០០០ដុល្លារអារមេរិក ដែលមានចំនួន ១០០.០០០ ភាគហ៊ុន ហើយត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម និងធនាគារកណ្តាល នៅថ្ងៃទី០២ ខែមករា ឆ្នាំ ២០១៨។

## ១៦. ចំណូលការប្រាក់

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូកការប្រាក់ពីៈ | | | | |
| កម្ចីពីអតិថិជន | ៣.០៣៨.៩៨២ | ១២.២១០.៦៣០ | ១.៩៣២.៥៣៤ | ៧.៨០១.៦៤០ |
| សមតុល្យនៅធនាគារកណ្តាល | ៣.០២២ | ១២.១៤២ | ៤៧.៥២៨ | ១៩១.៨៧០ |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៦០២ | ២.៤១៩ | - | - |
| | ៣.០៤២.៦០៦ | ១២.២២៥.១៩១ | ១.៩៨០.០៦២ | ៧.៩៩៣.៥១០ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ១៧. ចំណាយការប្រាក់

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កម្ចីពី៖ | | | | |
| កម្ចីពីភាគីពាក់ព័ន្ធ (កំណត់សម្គាល់២៥) | ៣៤២.៣៣៧ | ១.៣៧៥.៥១០ | ២២១.២១៦ | ៨៩៣.០៤៩ |
| កម្ចីពីភាគីមិនពាក់ព័ន្ធ | ៩២.១៩៥ | ៣៧០.៤៤០ | ៨៥.២៦៥ | ៣៤៤.២១៥ |
| | ៤៣៤.៥៣២ | ១.៧៤៥.៩៥០ | ៣០៦.៤៨១ | ១.២៣៧.២៦៤ |

## ១៨. ចំណូលកម្រៃ និងកម្រៃជើងសា

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូល និងកម្រៃជើងសា | ២២៦.៧៣៦ | ៩១១.០២៥ | ៩៥.៧៩៦ | ៣៨៦.៧២៩ |
| កម្រៃពិន័យបានមកពីការបង់ឥណទានមុន | ១១០.៧៨៧ | ៤៤៥.១៤២ | ៧០.៣៣៤ | ២៨៣.៩៣៨ |
| ប្រាក់ចំណូលផ្សេងៗ | ១៩៧.៦៣៩ | ៧៩៤.១១៤ | ៨៥.៥២២ | ៣៤៥.២៥២ |
| | ៥៣៥.១៦២ | ២.១៥០.២៨១ | ២៥១.៦៥២ | ១.០១៥.៩១៩ |

## ១៩. ចំណាយបុគ្គលិក

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បៀវត្សរ៍ និងប្រាក់រង្វាន់ | ១.១២៤.៣៤០ | ៤.៥១៧.៥៩៨ | ៩០៧.១២១ | ៣.៦៦២.០៤៨ |
| ចំណាយអតីតភាពការងារបុគ្គលិក | ៩២.០៦៧ | ៣៦៩.៩២៥ | - | - |
| ចំណាយបុគ្គលិកផ្សេងៗ | ៩៩.០៦៧ | ៣៩៨.០៥២ | ១០១.៤៤២ | ៤០៩.៥២១ |
| | ១.៣១៥.៤៧៤ | ៥.២៨៥.៥៧៥ | ១.០០៨.៥៦៣ | ៤.០៧១.៥៦៩ |

## ២០. រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២៣.៤៩២ | ៤៩៦.១៩១ | ១២២.៦៣៦ | ៤៩៥.០៨២ |
| រំលស់ទ្រព្យសកម្មអរូបី | ៣.២៤៦ | ១៣.០៤២ | ៤.៥៣៤ | ១៨.៣០៣ |
| | ១២៦.៧៣៨ | ៥០៩.២៣៣ | ១២៧.១៧០ | ៥១៣.៣៨៥ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ២១. ចំណាយទូទៅ និងចំណាយរដ្ឋបាល

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយទីតាំងជួល | ៧៤.០០៧ | ២៩៧.៣៦០ | ៥៨.១៣៧ | ២៣៤.៦៩៩ |
| ចំណាយកម្សាន្តបុគ្គលិក | ៥០.០០៦ | ២០០.៩២៤ | ៣១.៤០៦ | ១២៦.៧៨៦ |
| ចំណាយទំនាក់ទំនង | ៤២.៥៤៤ | ១៧០.៩៤២ | ២៩.៣៦៣ | ១១៨.៥៣៨ |
| ចំណាយជួសជុល និងថែទាំ | ៤១.១០២ | ១៦៥.១៤៨ | ១២.៩៨០ | ៥២.៤០០ |
| កម្រៃសេវាវិជ្ជាជីវៈ | ៣៨.៧៣០ | ១៥៥.៦១៧ | ២១.១៧៤ | ៨៥.៤៧៩ |
| ចំណាយប្រតិបត្តិការយានយន្ត | ៣៧.០៧២ | ១៤៨.៩៥៥ | ២៣.២៣៦ | ៩៣.៨០៤ |
| ចំណាយគ្រឿងបំពាក់តម្លៃទាប | ៣៦.៨៦៤ | ១៤៨.១២០ | ១៨.០៦៩ | ៧២.៩៤៥ |
| ចំណាយទឹកភ្លើង | ៣១.៩០៧ | ១២៨.២០២ | ២៥.១៩៦ | ១០១.៧១៦ |
| ចំណាយបរិក្ខារការិយាល័យ | ២៦.៧៨១ | ១០៧.៦០៦ | ២៤.៥១៥ | ៩៨.៩៦៧ |
| ចំណាយធ្វើដំណើរ និងកម្សាន្ត | ២១.៣៧៦ | ៨៥.៨៨៩ | ១១.២៨៥ | ៤៥.៥៥៨ |
| កម្រៃអាជ្ញាប័ណ្ណ | ១៩.៨៣៧ | ៧៩.៧០៥ | ១១.៥៦១ | ៤៦.៦៧២ |
| ចំណាយជួលផ្សេងៗ | ១៩.៤៣៥ | ៧៨.០៩០ | ៩.៦៩៣ | ៣៩.១៣១ |
| ប្រាក់រង្វាន់ថ្នាក់ដឹកនាំ | ១៨.៨០០ | ៧៥.៥៣៨ | ១៦.៨០០ | ៦៧.៨២២ |
| ចំណាយសន្តិសុខ | ១៣.៤១៩ | ៥៣.៩១៨ | ៣.៥៦០ | ១៤.៣៧២ |
| ចំណាយធនាគារ | ១០.៤៧៧ | ៤២.០៩៧ | ៥.៨៩៩ | ២៣.៨១៤ |
| កម្រៃ និងកម្រៃជើងសាពីកម្ចី | ៩.២៣៦ | ៣៧.១១០ | ២១ | ៨៥ |
| ចំណាយផ្សេងៗ | ៤១.៧៣១ | ១៦៧.៦៧៥ | ៣៨.៨៧១ | ១៥៦.៩២២ |
| | ៥៣៣.៣២៤ | ២.១៤២.៨៩៦ | ៣៤១.៧៦៦ | ១.៣៧៩.៧១០ |

## ២២. សំវិធានធនខាតលើការថយចុះតម្លៃនៃឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សំវិធានធនសម្រាប់ការខាតឥណទាន (កំណត់សម្គាល់៨) | ២៤៣.៥៦៥ | ៩៧៨.៦៤៤ | ៦៦.៦២៦ | ២៦៨.៩៦៩ |
| សំវិធានធន សម្រាប់សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ (កំណត់សម្គាល់៧) | ១.២០៣ | ៤.៨៣៤ | - | - |
| | ២៤៤.៧៦៨ | ៩៨៣.៤៧៨ | ៦៦.៦២៦ | ២៦៨.៩៦៩ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

### ២៣. ពន្ធលើប្រាក់ចំណេញ
### (ក) ចំណាយពន្ធលើប្រាក់ចំណូល

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធលើប្រាក់ចំណូលៈ | | | | |
| ពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ២៦៧.២០៦ | ១.០៧៣.៦៣៤ | ៨៤.៥០៨ | ៣៤១.៩៥៩ |
| ពន្ធពន្យារប្រាក់ចំណូល | (៧០.៤៨៧) | (២៨៣.២១៧) | - | - |
| | ១៩៦.៧១៩ | ៧៩០.៤១៧ | ៨៤.៥០៨ | ៣៤១.៩៥៩ |

### (ខ) ចំណូលពន្ធលើប្រាក់ចំណូលត្រូវបង់

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ដើមឆ្នាំ | ៦២.៩៨៤ | ២៥៤.២៦៦ | ៩៤.៩០៦ | ៣៨៣.១៣៦ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៦៧.២០៦ | ១.០៧៣.៦៣៤ | ៨៤.៥០៨ | ៣៤១.៩៥៩ |
| ពន្ធលើប្រាក់ចំណូលបានបង់ | (៩៦.៣៨១) | (៣៨៧.២៥៩) | (១១៦.៤៣០) | (៤៧០.០២៩) |
| | - | (១.១៩៦) | - | - |
| ចុងឆ្នាំ | ២៣៣.៨០៩ | ៩៣៩.៤៤៥ | ៦២.៩៨៤ | ២៥៤.២៦៦ |

### (គ) ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធលើប្រាក់ចំណូល និងចំណេញតាមគណនេយ្យៈ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | ៩២២.៩៣២ | ៣.៧០៨.៣៣៩ | ៣៨១.១០៨ | ១.៥៣៨.៥៣៣ |
| ពន្ធលើប្រាក់ចំណេញគណនាតាមអត្រា ២០% | ១៨៤.៥៨៦ | ៧៤១.៦៦៨ | ៧៦.២២២ | ៣០៧.៧០៨ |
| ផលប៉ះពាល់ពន្ធដែលធ្វើការកត់ត្រាឡើងវិញៈ | | | | |
| ចំណាយដែលមិនអាចកាត់កងតាមច្បាប់ពន្ធ | ១២.១៣៣ | ៤៨.៧៤៩ | ១១.០៣៨ | ៤៤.៥៦១ |
| ការលើកទឹកចិត្តផ្នែកពន្ធ | - | - | (២.៧៥២) | (១១.១១០) |
| | ១៩៦.៧១៩ | ៧៩០.៤១៧ | ៨៤.៥០៨ | ៣៤១.៩៥៩ |

ក្រោមច្បាប់សារពើពន្ធ ក្រុមហ៊ុនត្រូវបង់ពន្ធលើប្រាក់ចំណូលតាមអត្រា២០%។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

**២៣. ពន្ធលើប្រាក់ចំណេញ (ត)**

**(ឃ) ពន្ធពន្យារប្រាក់ចំណូល**

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធពន្យារទ្រព្យសកម្ម | ៧០.៤៨៧ | ២៨៣.២១៧ | - | - |
| បំណុលពន្ធពន្យារ | - | - | - | - |
| ពន្ធពន្យារទ្រព្យសកម្មសុទ្ធ | ៧០.៤៨៧ | ២៨៣.២១៧ | - | - |

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្មក្នុងឆ្នាំមានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ដើមឆ្នាំ | - | - | - | - |
| ឥណទានចំណេញ ឬខាត | ៧០.៤៨៧ | ២៨៣.២១៧ | - | - |
| ចុងឆ្នាំ | ៧០.៤៨៧ | ២៨៣.២១៧ | - | - |

**(ខ) ពន្ធពន្យារទ្រព្យសកម្ម**

| | សំវិធានធនខាតឥណទានទូទៅ | រំលស់ពន្លឿន | ភាគពួកិច្ច អត្ថប្រយោជន៍បុគ្គលិក | សរុប |
|---|---|---|---|---|
| សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ | | | | |
| ដើមឆ្នាំ | - | - | - | - |
| កត់ត្រាជាឥណទានក្នុងរបាយការណ៍ ចំណេញ ឬខាត | ៤៦.៥៦៥ | ៥.៥០៩ | ១៨.៤១៣ | ៧០.៤៨៧ |
| ចុងឆ្នាំ | ៤៦.៥៦៥ | ៥.៥០៩ | ១៨.៤១៣ | ៧០.៤៨៧ |
| សមមូលនឹងពាន់រៀល | ១៨៧.០៩៩ | ២២.១៣៥ | ៧៣.៩៨៣ | ២៨៣.២១៧ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ២៤. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | ១០៨.៦៧៤ | ៤៣៦.៦៥៣ | ១៧១.១៤៨ | ៦៩០.៩២៤ |
| សាច់ប្រាក់ជាមួយភ្នាក់ងារ | ១៦៤.១៩១ | ៦៥៩.៧១៩ | ១០៧.៨៧២ | ៤៣៥.៥១៩ |
| សមតុល្យនៅធនាគារកណ្តាល-គណនីចរន្ត | ២.៧៩៦ | ១១.២៣៤ | ១.៤៧១ | ៥.៩៣៨ |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ-គណនីចរន្ត | ១០៩.២២៨ | ៤៣៨.៨៧៨ | ៣១៦.៣៧០ | ១.២៧៧.១៨៦ |
| | ៣៨៤.៨៨៩ | ១.៥៤៦.៤៨៤ | ៥៩៦.៨៧១ | ២.៤០៩.៥៦៧ |

## ២៥.ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធ និងទំនាក់ទំនងរបស់ពួកគេជាមួយក្រុមហ៊ុន មានដូចខាងក្រោម៖

| **ទំនាក់ទំនង** | **ភាគីពាក់ព័ន្ធ** |
|---|---|
| ម្ចាស់ក្រុមហ៊ុន | លោក តាំង ងួន<br>លោក តាំង ហុង<br>លោក ជាង ស៊ីវណ្ណលាង<br>លោក ភួង ធីទៀង<br>លោក ហ៊ុន ស៊ីចាវ |
| សមាជិកជិតស្និតនៃម្ចាស់ក្រុមហ៊ុន | សមាជិកជិតស្និតនៃម្ចាស់ក្រុមហ៊ុន គ្រួសារដែលមានឥទ្ធិពល ឬត្រួតពិនិត្យក្រុមហ៊ុន |
| បុគ្គលិកថ្នាក់គ្រប់គ្រងសំខាន់ៗ | ក្រុមប្រឹក្សាភិបាលទាំងអស់របស់ក្រុមហ៊ុន ជាអ្នកដែលធ្វើការសម្រេចចិត្តសំខាន់ៗ ទៅលើយុទ្ធសាស្រ្តដឹកនាំក្រុមហ៊ុន និងបុគ្គលិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់ (រាប់ទាំងគ្រួសារជិតដិតរបស់ពួកគេផងដែរ)។ |

ក្រុមហ៊ុនបានចូលរួមប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធក្នុងប្រតិបត្តិការអាជីវកម្មធម្មតា។ កម្រិតប្រតិបត្តិការភាគីពាក់ព័ន្ធ សមតុល្យដែលមិនទាន់ជម្រះនៅចុងឆ្នាំ ចំណាយ និងចំណូលដែលពាក់ព័ន្ធសម្រាប់ដំណាច់ឆ្នាំមានដូចខាងក្រោម៖

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨**

## ២៥. ប្រតិបត្តិការតាភាគីពាក់ព័ន្ធ (ត)

### (ក) ឥណទានរបស់គណៈគ្រប់គ្រងសំខាន់ៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| ថ្ងៃទី១ ខែមករា | ២៤.៩៨១ | ១០០.៣៧៥ | ២.១៥៩ | ៨.៧១៦ |
| ទិញបន្ថែម | ៩៥.០០០ | ៣៨១.៧១០ | ២៦.៤០០ | ១០៦.៥៧៧ |
| ចំណូលការប្រាក់ | ៥.៤៥២ | ២១.៩០៦ | ១.១៨៦ | ៤.៧៩០ |
| បង់សងកម្ចី | (៣៦.១៣៧) | (១៤៥.២០០) | (៤.៧៦៤) | (១៩.២៣៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - |
| សមតុល្យចុងឆ្នាំ | ៨៩.២៩៦ | ៣៥៨.៧៩១ | ២៤.៩៨១ | ១០០.៨៥០ |

